# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៧៤៥៩ អកក.សជណ.អតធ.ឈ

## សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ០២ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យផែនការផ្គត់ផ្គង់សម្ភារ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- សម្រាប់ បុគ្គលិករដ្ឋបាល ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្ររងគ្រប់គ្រង ឬ បរិញ្ញាបត្ររងរដ្ឋបាលសាធារណៈ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel ស្ទាត់ជំនាញ
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ។

២- សម្រាប់ បុគ្គលិក ផ្នែកគ្រប់គ្រងការផ្គត់ផ្គង់សម្ភារអគ្គិសនី ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel ស្ទាត់ជំនាញ
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី( ១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ( ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត )ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

* - **ទីកន្លែងទទួលពាក្យ** :សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

* -**ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១៤

ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**